# លក្ខខណ្ឌយោង
# ទីប្រឹក្សាជាតិរៀបចំគេហទំព័រ
# ជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ២៥ រាជធានី-ខេត្ត

រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាំងពីចុងឆ្នាំ ២០០៤ ក្នុងទិសដៅលើកកម្ពស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាឆ្ពោះទៅរកកម្រិតស្តង់ដាអន្តរជាតិ តាមរយៈអភិក្រម ៤ជំហាន និង៤ដំណាក់កាល។ ដំណាក់កាលទី១ដែលត្រូវបានផ្តោតលើការបង្កើនភាពជឿទុកចិត្ត នៃថវិកា និងរៀបចំ លក្ខណៈសម្បត្តិសម្រាប់ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុត្រូវបានបញ្ចប់ ដោយជោគជ័យ ជាមួយនឹងការសម្រេចបាន នូវភាពជឿទុកចិត្តនៃថវិកាជាសារវន្ត តាមរយៈការអនុវត្តផែនការសកម្មភាពរួមទី១ នៅចុងឆ្នាំ២០០៨ មុនពេលដំណាក់- កាលទី២ត្រូវបានដាក់ឲ្យអនុវត្តដោយផ្តោតលើការបង្កើនគណនេយ្យភាព ហិរញ្ញវត្ថុ និងការរៀបចំលក្ខណៈសម្បត្តិសម្រាប់ការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ តាមរយៈ ការដាក់ឲ្យអនុវត្តពេញលេញនូវផែនការសកម្មភាពរួមទី២ នៅដើមឆ្នាំ២០០៩។ ដោយសារភាពស្មុគស្មាញ និងបញ្ហាហិរញ្ញប្បទាន ផែនការសកម្មភាពរួមទី២ ត្រូវបានត្រួតពិនិត្យ ឡើងវិញជាច្រើនដងនៅក្នុងឆ្នាំ២០០៩ និងឆ្នាំ២០១០ ហើយទីបំផុតយុទ្ធសាស្ត្រ ៣+២ ត្រូវបានកសាងឡើងនៅឆ្នាំ២០១១ ដើម្បីផ្តោតការយកចិត្តទុកដាក់លើការរៀបចំលក្ខណៈសម្បត្តិ សម្រាប់ការដាក់ឲ្យអនុវត្តគម្រោងគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

ទន្ទឹមនឹងនេះ ក្នុងគោលដៅបង្កើនសមត្ថភាពស្ថាប័ន និងប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការប្រតិបត្តិការងារក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំកែសម្រួលរចនាសម្ព័ន្ធស្ថាប័ន និងពង្រឹងសមត្ថភាពធនធានមនុស្ស ជាពិសេស ដើម្បីឆ្លើយតបទៅនឹងតម្រូវការចំបាច់សម្រាប់ការអនុវត្តប្រព័ន្ធថ្មីដែលបាន និងកំពុងដាក់ឲ្យ អនុវត្ត ជាបណ្តើរៗ ពីមួយ ជំហានទៅមួយជំហាន ។ លើសពីនេះទៅទៀត នៅឆ្នាំ២០១៤ និងឆ្នាំ២០១៥ ខាងមុខនេះ គឺជាឆ្នាំដែលត្រូវចាប់ផ្តើម កសាងឲ្យចេញជារូបរាងពិតប្រាកដនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុមួយ តាមរយៈការផ្តុំបញ្ចូល គ្នានូវផ្នែកនីមួយៗ ដែលបានរៀបចំត្រៀមលក្ខណៈដោយឡែកៗ ពីគ្នាកន្លងមក ហើយដែលត្រូវដាក់ឲ្យដំណើរការពេញ លេញចាប់ពីឆ្នាំ២០១៥ទៅ ។

រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា បានបន្តផ្តោតលើគោលដៅអាទិភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ បន្ទាប់ពីដាក់ឱ្យអនុវត្ត**«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥»** និងផែនការសកម្មភាព លម្អិតនៃយុទ្ធសាស្ត្រនេះ ដែលជាស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសា-ធារណៈ, រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ឱ្យអនុវត្ត «យុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៥», «យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធ គ្រប់គ្រងការ វិនិយោគសាធារណៈ ២០១៩-២០២៥», «យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥» និង «យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩-២០២៥» ។ ក្នុងន័យគាំទ្រការអនុវត្ត យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព, ការផ្តល់ប្រឹក្សា ផ្តល់ជំនួយ បច្ចេកទេស ផ្តល់កិច្ចសហការ និងសម្របសម្រួលដល់គ្រប់ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន នាយកដ្ឋាន ព្រមទាំងក្រសួង-ស្ថាប័ន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិពីសំណាក់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ

សាធារណៈ ដែលមានអគ្គលេខាធិការដ្ឋានជាសេនាធិការក្នុងការបំពេញការងារទាំងនេះក្នុងនាមគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) គឺជាសេនាធិការជូនគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) ក្នុងការដឹកនាំរៀបចំសម្របសម្រួលការអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលព្រមទាំងក្នុងការសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយដៃគូ អភិវឌ្ឍន៍ពាក់ព័ន្ធ។

ដើម្បីបំពេញមុខងាររបស់ខ្លួនជាសេនាធិការប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពជូន **គ.ហ.ស.**, **អ.គ.ហ.** បានរៀបចំនូវកិច្ចដំណើរនៃការអភិវឌ្ឍវេបសាយរបស់មន្ទីរសេដ្ឋកិច្ចទាំង **២៥** រាជធានី-ខេត្ត ដើម្បីកែលំអរនូវការគ្រប់គ្រង រចនាសម្ព័ន្ធ និងការប្រមូលទិន្នន័យពីគ្រប់មន្ទីរសេដ្ឋកិច្ចដោយផ្តោតលើគោលបំណងសំខាន់ៗរួមមានៈ **(១).**ផ្តល់ភាពងាយ ស្រួលក្នុងការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តិ, **(២).**ងាយស្រួលប្រមូលទិន្នន័យសេដ្ឋកិច្ចរបស់មន្ទីរសេដ្ឋកិច្ចទាំង ២៥ រាជធានី-ខេត្ត, **(៣).**គ្រប់គ្រងគណនេយ្យភាព និងតម្លាភាពថវិកា, **(៤).**ងាយស្រួលផ្តល់ជូនសេវាសាធារណៈតាមបែប អេឡិចត្រូនិច (E-Service), **(៥).**ដើម្បីងាយស្រួលការជូនដំណឹង និងពតិមានផ្សេងៗរបស់មន្ទីររាជធានីខេត្ត។

ក្នុងន័យនេះ **អ.គ.ហ.** មានតម្រូវការជ្រើសរើសទីប្រឹក្សាជាតិ ចំនួន០១រូប ដើម្បីរៀបចំគេហទំព័រជូនមន្ទីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ២៥ រាជធានី-ខេត្ត ដែលមានមុខងារ ភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម÷

**តម្រូវការមន្ទីរសេដ្ឋកិច្ច**

តាមរយៈតម្រូវការក្នុងការរៀបចំគេហទំព័ររបស់មន្ទីរសេដ្ឋកិច្ច **អ.គ.ហ.** បានរៀបចំនូវសេចក្តីព្រាងរួមគ្នាជា មួយមន្ទីរសេដ្ឋកិច្ចរាជធានី-ខេត្ត ដើម្បីផ្តល់ជាគន្លឹះក្នុងការរៀបចំមាតិកាអោយត្រូវទៅតាមស្តង់ដា និងជាតម្រូវការដល់ អ្នកប្រើប្រាស់។ជាងនេះទៅទៀតការរៀបចំគេហៈទំព័របានកំណត់យកនូវមាតិកាជាមូលដ្ឋានរួមមាន÷

- ទំព័រដើម
- អំពីមន្ទីរសេដ្ឋកិច្ច
- លិខិតបទដ្ឋានគតិយុត្តិ
- ទាយយកឯកសារ (E-Service)
- ព័តិមានសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត
- គណនេយ្យភាពសមិទ្ធិកម្ម
- ដំណឹង/ព្រឹត្តិការណ៍
- ទំនាក់ទំនង

*បញ្ជាក់÷ រាល់មាតិកាទាំងអស់អាចធ្វើការផ្លាស់ប្តូរ និងមានភាពបត់បែនទៅតាមការរៀបចំប្រភេទមាតិកាផ្សេងៗគ្នានៅ គ្រប់មន្ទីរសេដ្ឋកិច្ច រាជធានី-ខេត្ត ទាំង២៥។

**លក្ខណៈរបស់វេបសាយ**

- ឈ្មោះ Domain
- ពតិមានអង្គភាព
- មុខងារស្វែងរក
- ឡូគូអង្គភាព (Logo)
- របាររុករក
- ពណ៌មានរូបភាព
- តំណភ្ជាប់យោង
- គេហទំព័រឌីណាមិក (Dynamic Website)
- Platform គាំទ្រគ្រប់ប្រភេទ Screen Device និងកុំព្យូទ័រ
- គ្រប់គ្រងចំនួនអ្នកចូលទស្សនា
- ពតិមានទំនាក់ទំនង
- ពតិមានសមាជិក
- ភាសាគាំទ្រក្នុងគេហទំព័រ(ភាសាខ្មែរ និងអង់គ្លេស)

**លក្ខណៈសម្បត្តិរបស់ទីប្រឹក្សា**

| គុណវុឌ្ឍិគន្លិះ | តម្រូវការ |
|---|---|
| **១. តម្រូវការបច្ចេកទេស** | - ជំនាញក្នុងវិភាគលើ Business Process ក្នុងការរៀបចំគេហទំព័រ<br>- ជំនាញក្នុងការរៀបចំ Prototype Documents និងការរចនា UI/UX<br>- ជំនាញក្នុងការវិភាគប្រព័ន្ធ និងរចនាគេហទំព័រ<br>- ជំនាញក្នុងការ សរសេរ និងប្រើប្រាស់ PHP(Laravel Framwork), MySQL, JQuery, Responsive Design, Joomla CMS, Wordpress, Drupal, VueJs<br>- មានចំណេះដឹងយ៉ាងតិច ១ឆ្នាំ ជាមួយ DevOps ឬ tools ដូចជា Jira, Git Repository, Jenkins, ឬ Sonarqube កាន់តែប្រសើ<br>- មានចំណេះដឹងទូលំទូលាយក្នុងការអភិវឌ្ឍគេហទំព័រនៅក្នុងប្រទេសកម្ពុជា |

| | |
|---|---|
| **២. គុណវុឌ្ឍិទូទៅ** | - យ៉ាងហោចណាស់មានសញ្ញាបត្រកម្រឹតបរិញ្ញាបត្រ ជំនាញវិទ្យាសាស្ត្រកុំព្យូទ័រ និង សញ្ញាបត្រប្រហាក់ប្រហែល<br>- បទពិសោធន៍យ៉ាងតិច ៣ ឆ្នាំ ក្នុងការអភិវឌ្ឍគេហទំព័រ<br>- បទពិសោធន៍ ២ ឆ្នាំ ជាមួយការអភិវឌ្ឍដោយប្រើប្រាស់ Laravel Framework<br>- បទពិសោធន៍ ១ ឆ្នាំ ទាក់ទង Cloud Platform, Linux and Ubuntu Server<br>- មានបទពិសោធន៍ធ្វើការជាក្រុម និងការងារឆ្លងក្រុម<br>- មានភាពបត់បែនក្នុងការដោះស្រាយបញ្ហា<br>- មានចំណេះដឹងផ្នែក Agile Development(Scrum) កាន់តែប្រសើរ<br>- មានចំណេះដឹងក្នុងការអភិវឌ្ឍន៍ Mobile Development កាន់តែប្រសើរ<br>- ចេះលើកទឹកចិត្តខ្លួនឯង និងមានទទួលខុសខ្ពស់ចេះច្នៃប្រឌិត និងមានឆន្ទៈក្នុងការរៀនបច្ចេកវិទ្យាថ្មីៗ<br>- ទទួលខុសត្រូវចំពោះការអភិវឌ្ឍន៍សមាសធាតុឬម៉ូឌុលសំខាន់ៗ និង ចូលរួមចំណែកក្នុងការរចនានិងថែទាំគម្រោង<br>- មានបទពិសោធន៍ក្នុងការបង្កើតនិងរចនាវេបសាយដែលស្រដៀងនឹងកម្មវិធីនិងការគ្រប់គ្រងទិន្នន័យ<br>- មានចំណេះដឹងផ្នែកភាសាអង់គ្លេសដែលអាចនិយាយ និងសរសេរបានល្អ |
| **៣. បទពិសោធន៍ ពាក់ព័ន្ធជាមួយតម្រូវការបច្ចេកទេស** | មានបទពិសោធន៍យ៉ាងតិច ៥ ឆ្នាំ ទាក់ទងទៅនឹងការរៀបចំគម្រោង ការអភិវឌ្ឍគេហទំព័រ និងការរៀបចំ Database Management ជូនស្ថាប័នសាធារណៈ និងស្ថាប័នឯកជន ធំៗ |
| **៤. បទពិសោធន៍ ពាក់ព័ន្ធការបណ្តុះបណ្តាលលើគេហទំព័រ** | - អាចរៀបចំសៀវភៅណែនាំអ្នកប្រើប្រាស់ និងផ្តល់ការបណ្តុះបណ្តាលដោយ ប្រើវិធីសាស្ត្រ ក្នុងការបង្រៀន។<br>- មានជំនាញធ្វើបទបង្ហាញល្អដោយប្រើប្រាស់កម្មវិធី Power Point និងអាចរៀបចំ បទបង្ហាញដោយខ្លួនឯង។<br>- មានជំនាញលើកទឹកចិត្ត។ |

## លក្ខខណ្ឌបច្ចេកទេសផ្សេងៗរបស់គេហទំព័រ

### ១. ប្រព័ន្ធសុវត្ថិភាពគេហទំព័រ

ដើម្បីធានាដល់សុវត្ថិភាពគេហទំព័រ និងការរក្សាទុកទិន្នន័យទីប្រឹក្សា និងត្រូវរៀបចំវិធីសាស្ត្រដូចខាងក្រោម÷

១. បន្ថែម HTTPS និង SSL Certificate

២. ការប្រើប្រាស់លេខសម្ងាត់

៣. ប្រើគេហទំព័រសុវត្ថិភាព

៤. កត់ត្រាការចូលប្រើនិងសិទ្ធិរដ្ឋបាលរបស់អ្នកប្រើប្រាស់

៥. ផ្លាស់ប្តូរការកំណត់លំនាំដើម CMS (Setting Configuration)

៦. ធ្វើផែនការបម្រុងទុក (Auto Backup Database)

៧. ការកំណត់សិទ្ធ (Firewall Rules)

៨. រឹតបណ្តាញសន្តិសុខបណ្តាញ (Tighten Network Security)

### ២. វិសាលភាពនៃការងារ

សេវាកម្មដែលត្រូវការ និងសកម្មភាពដើម្បីរៀបចំគេហទំព័ររួមមាន÷

<u>**ការអភិវឌ្ឍគេហទំព័រ**</u>

- ធានាសុវត្ថិភាពតំបន់បណ្តាញដែលមានស្រាប់ក្នុងកំឡុងពេលផ្លាស់ប្តូរទៅ Platformថ្មី និងអភិរក្សមាតិកា និងមុខងារគេហទំព័របច្ចុប្បន្នទាំងអស់។
- រៀបចំវេបសាយទៅជាប្រព័ន្ធគ្រប់គ្រងមាតិកា (CMS) ស្តង់ដារ (ឧ. Wordpress, Drupal ឬ Joomla)។
- ប្រើបច្ចេកទេសសាមញ្ញ ដើម្បីរចនាទម្រង់គេហទំព័រផ្សាភ្ជាប់ជាមួយអ្នកប្រើប្រាស់ដែលធ្លាប់ប្រើប្រាស់កន្លងមក ជាមួយគេហទំព័រស្តង់ដាពីដើម មុនឈានដល់ការអនុវត្តន៍នូវមុខងារសំខាន់ៗ ដូចជាការរៀបចំរចនាសម្ព័ន្ធមីនុយនាវាចរណ៍។
- បង្កើនប្រសិទ្ធភាពគេហទំព័រសម្រាប់អ្នកប្រើប្រាស់ ដែលនិងត្រូវផ្សាភ្ជាប់ជាមួយកម្រិតល្បឿន លឿន។
- បង្កើត API បើកចំហរលើមូលដ្ឋានទិន្នន័យ ដើម្បីផ្សាភ្ជាប់ជាមួយ Platform កណ្តាលរបស់ GSC ក្នុងការ ប្រមូលទិន្នន័យពីគ្រប់មន្ទីសេដ្ឋកិច្ចទាំង ២៥ រាជធានី-ខេត្ត នៅពេលទិន្នន័យត្រូវបញ្ចូលនៅតាម មូលដ្ឋានរបស់មន្ទីសេដ្ឋកិច្ច។
- អនុវត្តមុខងារ “ប៊្លុក” ជាមូលដ្ឋានជាមួយនឹងរួមបញ្ចូលគ្នាទៅកាន់ បណ្តាញសង្គមនៅពេលដាក់មាតិកាគេហទំព័រជាសាធារណៈ ដែលជាមុខងារជួយសម្រួលដល់ការផ្សាយព័ត៌មានយ៉ាង ទូលំទូលាយ តាមរយៈ បណ្តាញសង្គម នៅពេលពត៌មានដាក់ជាសាធារណៈ។

- តំបន់បណ្តាញត្រូវតែអាចប្រើប្រាស់ និងគាំទ្រជាមួយកម្មវិធីរុករកគេហទំព័របច្ចុប្បន្នដូចជា (Firefox, Internet Explorer, Safari, និង Chrome) ក៏ដូចជាកម្មវិធីរុករកលើបណ្តាញអ៊ីនធឺណិតផ្សេងទៀត។
- បន្ថែមមុខងារស្វែងរកដ៏ទូលំទូលាយទៅកាន់គេហទំព័រ ដែលអាចអោយអ្នកប្រើប្រាស់អ៊ីនធឺណិតអាចស្វែងរកគេហទំព័របានយ៉ាងងាយស្រួល និងឆាប់រហ័ស។

**ការរៀបចំ Hosting សម្រាប់គេហទំព័រ**

ក្នុងអំឡុងពេលនៃការអភិវឌ្ឍគេហទំព័រ ទីប្រឹក្សានិងត្រូវរៀបចំ Web Hosting ជាមុនដែលបំពាក់ជាមួយ SSL(Security Socket Layer) ដែលជាឧបករណ៍ដើម្បីការពារទិន្នន័យ និងកូដពីការវាយលុករបស់ជនអនាមឹកដែល មានបំណងចង់ចូលបំផ្លាញ ទិន្នន័យឬបំណងណាមួយមិនល្អក្នុងអំឡុងពេលអភិវឌ្ឍ។

## ៣. ពេលវេលា និងគោលដៅ

**ការបែងចែកពេលវេលានៃការរៀបចំគេហទំព័រ**

រយៈពេលនៃការរៀបចំ និងអភិវឌ្ឍគេហទំព័រជូនមន្ទីសេដ្ឋកិច្ច ទាំង ២៥ រាជធានី-ខេត្ត និងប្រើប្រាស់ពេលវេលា យ៉ាងតិច ៦ ខែ ដែលត្រូវរៀបចំតាមដំណាក់កាល។ ដើម្បីកំណត់ពេលវេលាអោយត្រឹមត្រូវ ទីប្រឹក្សាត្រូវរៀបចំ ជាសេចក្តីព្រាងនិងកាលវិភាគនៃការចាប់ផ្តើមរហូតដល់ការបញ្ចប់ដើម្បីឆ្លើយតមទៅនឹងដំណាក់នីមួយៗ ដោយត្រូវ ពិនិត្យក្នុងកិច្ចដំណើរដូចខាងក្រោម÷

| | |
|---|---|
| ***ដំណាក់កាលទី១÷**<br>កំណត់ពេលវេលានៃការរៀបចំ Mock Screen និង Prototype | ទម្រង់ Mock Screen និងPrototype ត្រូវរៀបចំ និងទទួលយក នូវរូបភាពដែលបានរចនា ដើម្បីទទួលយកបន្ទាប់ពីកែប្រែរួច ដោយក្រុមការងារ **អ.គ.ហ.** |
| ***ដំណាក់កាលទី២÷**<br>កំណត់ពេលវេលានៃការរៀបចំ រចនាសម្ព័ន្ធទិន្នន័យ | រចនាសម្ព័ន្ធរបស់គេហទំព័រ និងត្រូវផ្តល់ជូនដោយក្រុមការងារ **អ.គ.ហ.** ដើម្បីផ្តល់ជូនទីប្រឹក្សាយកទៅវិភាគ និងបំលែងទៅជា Database Structure។ |
| ***ដំណាក់កាលទី៣÷**<br>កំណត់ពេលវេលានៃបែងចែកក្រុមការងារអភិវឌ្ឍ | ទីប្រឹក្សា និងត្រូវបែងចែកទៅតាមទួនាទីដើម្បីអោយការអភិវឌ្ឍ ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។ |
| ***ដំណាក់កាលទី៤÷**<br>កំណត់ពេលវេលានៃការចាប់ផ្តើមអភិវឌ្ឍគេហទំព័រ | ពេលវេលានៃការចាប់ផ្តើមអភិវឌ្ឍគេហទំព័រ និងត្រូវផ្តល់ជូនពីប្រឹក្សាដើម្បីបញ្ចប់គម្រោងអោយទាន់ពេលវេលា |
| ***ដំណាក់កាលទី៥÷**<br>កំណត់ពេលវេលានៃណាត់ជួបព្រឹក្សាយោបល់ | ក្រុមការងារបច្ចេកទេស **អ.គ.ហ.** និងរៀបចំពីកាលវិភាគពិភាក្សាពីវឌ្ឍនៈភាពរៀងរាល់ចុងសប្តាហ៍(ថ្ងៃសុក្រ)ដើម្បីពិនិត្យលើ បញ្ហាប្រឈម និងផ្តល់ដំណោះស្រាយរួមគ្នា។ |
| ***ដំណាក់កាលទី៦÷**<br>កំណត់ពេលវេលានៃការបញ្ចប់ និងដាក់ដំណើរការ | ការបញ្ចប់ និងដាក់អោយដំណើរការនូវគេហទំព័របន្ទាប់ពីពិនិត្យ និងសាកល្បងជោគជ័យក្នុង ដំណាក់កាល |

| | |
|---|---|
| | ជាក់លាក់។ |

<u>គោលដៅ</u>

គោលដៅនៃការរៀបចំគេហទំព័រផ្តល់ជូនគ្រប់មន្ទីរសេដ្ឋកិច្ច រាជធានី-ខេត្តដើម្បីមានជាមូលដ្ឋានក្នុងការរៀបចំ មាតិកាគេហទំព័ររបស់ខ្លួន។

## ៤. ការកំណត់សិទ្ធិក្នុងការប្រើប្រាស់គេហទំព័រ

ការកំណត់សិទ្ធិក្នុងការគ្រប់គ្រងគេហទំព័រ ដើម្បីរៀបចំគេហទំព័រអោយត្រូវទៅតាមតួនាទី, ប្រភេទ មាតិកា និង ពត៌មានដែលជាតួនាទីរបស់មន្ទីរសេដ្ឋកិច្ចត្រូវរៀបចំក្នុងគេហទំព័ររបស់ខ្លួន។ដូចនេះទីប្រឹក្សាត្រូវធានាក្នុងការគ្រប់គ្រង សិទ្ធិប្រើប្រាស់របស់បុគ្គល និងកត់ត្រាដោយស្វ័យប្រវត្តពីប្រវត្តនៃការបញ្ចូលទិន្នន័យ ឬ ប្រវត្តប្រត្តិបត្តិការណ៍ផ្សេងៗ ដើម្បីបង្ការក្នុងការចូលទៅបំផ្លាញ ឬកែប្រែដោយប្រការណាមួយ។ ដើម្បីបង្កភាពងាយស្រួលក្នុងការគ្រប់គ្រងសិទ្ធទីប្រឹក្សា គួរៀបចំប្រភេទសិទ្ធដែលត្រូវរៀបចំតាមប្រភេទដូចខាងក្រោម÷

| | |
|---|---|
| ១. អ្នកគ្រប់គ្រងគេហទំព័រ (System Administrator) | ▪ មានសិទ្ធគ្រប់គ្រង និងសម្រេចកិច្ចដំណើរការទាំងមូលរបស់ គេហទំព័រ |
| ២. អ្នកនិពន្ធមាតិកា (Content Editor) | ▪ មានសិទ្ធបញ្ចូលទិន្នន័យ និងកែសម្រួលមាតិកា |
| ៣. អ្នកត្រួតពិនិត្យមាតិកា (Content Monitor) | ▪ មានសិទ្ធត្រួតពិនិត្យអក្ខរាវិរុទ្ធ ក្នុងគេហទំព័រ |
| ៤. អ្នកគ្រប់គ្រងរបាយការណ៍ពត៌មាន (Reporting Controller) | ▪ មានសិទ្ធទាយយករបាយការណ៍ និងបោះពុម្ភរបាយការណ៍ |

## ៥. ការគាំទ្រ និងថែទាំ

បន្ទាប់ពីអភិវឌ្ឍរួច និងដាក់អោយដំណើរការជាផ្លូវការនូវគេហទំព័រ **អ.គ.ហ.** នឹងបន្តធ្វើការជាមួយទីប្រឹក្សាដើម្បី គាំទ្រ និងថែទាំគេហទំព័ររបស់មន្ទីរសេដ្ឋកិច្ច ក្នុងការរក្សាបាននូវពត៌មានសុវត្ថិភាព និងស្ថេរភាពនៃការប្រើប្រាស់។ ការថែទាំនេះ ទីប្រឹក្សានិងបន្តធ្វើយ៉ាងតិច ៦ ទៅ ១២ ខែ បន្ទាប់ពីដាក់ដំណើរការជាផ្លូវការ។

## ៦. ការផ្ទេសិទ្ធកាន់កាប់ Source Code

- ប្រភព Source Code ដែលបានអភិវឌ្ឍទាំងអស់ទីប្រឹក្សានឹងត្រូវប្រគល់ទៅឱ្យ **អ.គ.ហ.** ក្នុងការកាន់កាប់បន្ត។
- ធានារាល់ Source Code ដែលប្រគល់ជូន **អ.គ.ហ.** និងមិនមានការ Encryption និងអាចកែប្រែបានទៅថ្ងៃ អនាគត
- រចនាសម្ព័ន្ធ Source Code ដែលរៀបចំដោយទីប្រឹក្សាត្រូវរៀបចំអោយមានលក្ខណៈ ស្តង់ដា និងមានការរៀបចំ Comment Line ត្រឹមត្រូវដើម្បីផ្តល់ភាពងាយស្រួលនៅពេលកែសម្រួលពេលក្រោយ។
- ត្រូវរៀបចំឯកសារបន្ទាប់ពីអភិវឌ្ឍរួចរាល់ក្នុងការផ្តល់ជូន **អ.គ.ហ.** ដើម្បីជាឯកសារយោង

## ៧. ការបណ្តុះបណ្តាល

ក្រោយពីបញ្ចប់ការអភិវឌ្ឍគេហទំព័ររបស់មន្ទីរសេដ្ឋកិច្ច ទីប្រឹក្សាត្រូវធ្វើបទបង្ហាញជូនប្រធាន, អនុប្រធានមន្ទីរ សេដ្ឋកិច្ច និងមន្ត្រីអមទទួលបន្ទុកថែទាំគេហទំព័រ និងការបញ្ចូលទិន្នន័យនឹងត្រូវបានរៀបចំពីសំណាក់ទីប្រឹក្សា។ សហការណ៍ជាមួយ **អ.គ.ហ.** ក្នុងការជូន ដំណឹងជាមុននឹងធ្វើការបណ្តុះបណ្តាល។ សម្ភារៈសម្រាប់ការបណ្តុះបណ្តាល រួមមាន សៀវភៅនៃការប្រើប្រាស់ និងវីដេអូនៃការបញ្ចូលទិន្នន័យត្រូវបានផ្តល់ជូនយ៉ាងហោចអោយបានមុខបីថ្ងៃនៃ ការបណ្តុះបណ្តាល។ ទីប្រឹក្សាត្រូវធានាក្នុងការបង្ហាត់បង្រៀនប្រកបដោយក្រមសិលធម៌ និងធានាបាននូវ គុណភាពនៃការបង្ហាត់បង្រៀន និងត្រូវទទួលយកគុណភាពនៃការបង្រៀនពីសំណាក់មន្ត្រីទទួលបន្ទុកគ្រប់គ្រង ទិន្នន័យ របស់មន្ទី សេដ្ឋកិច្ចទាំង ២៥ រាជធានី-ខេត្ត។

*<u>បញ្ជាក់</u>÷* លក្ខខណ្ឌបច្ចេកទេសស្តីពីការរៀបចំគេហទំព័រជូនមន្ទីរសេដ្ឋកិច្ច រាជធានី-ខេត្ត ទាំង២៥ មានចែងនៅក្នុង លក្ខខណ្ឌយោង និងឯកសារបច្ចេកទេសបន្ថែម ដូចជូនភ្ជាប់មកជាមួយ។